-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-យោងតាមការចាំបាច់

## សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ម៉ុម ជីមហ៊ុយ** រដ្ឋលេខាធិការ នៃក្រសួងអប់រំយុវជន និង កីឡា ជំនួសឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋាន ដែលជាប់អញ្ជើញទៅបំពេញបេសកកម្ម នៅប្រទេស អូស្ត្រាលី ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៤ ។

**ប្រការ ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថ លេខានិង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៤*

## សារាចរលេខ ០៤ សរ

## ស្តីពីក្របខ័ណ្ឌសមត្ថកិច្ចក្នុងការសំរេច របស់ប្រធានក្រសួងស្ថាប័ន

យោងតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ រាជរដ្ឋាភិបាលបានសង្កេតឃើញថា កន្លងមកមានក្រសួងស្ថាប័នមួយចំនួនបានធ្វើការសំរេច ដោយខ្លួនឯងក្នុងការចេញលិខិតបទដ្ឋាន មានលក្ខណៈមិនសមស្របទៅនឹងច្បាប់និងគោលការណ៍របស់រាជរដ្ឋាភិបាលដែលជាហេតុនាំអោយមានឥទ្ធិពលមិនល្អដល់ការងារដឹកនាំ គ្រប់គ្រងរបស់រាជរដ្ឋាភិបាលព្រមទាំងធ្វើអោយប៉ះពាល់ខូច ខាតដល់ផលប្រយោជន៍ជាតិទៀតផង ។

ដើម្បីរក្សាបាននូវប្រសិទ្ធភាពដឹកនាំព្រមទាំងការពារបាននូវផលប្រយោជន៍ជាតិ និង ពង្រឹងនូវវិន័យការងាររបស់សមាជិករាជរដ្ឋាភិបាល រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួងស្ថាប័នដូចខាងក្រោមនេះ :

១- ប្រធានក្រសួងស្ថាប័ននិមួយៗ ត្រូវប្រតិបត្តិអោយបានត្រឹមត្រូវតាម ក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួនដែលកំណត់ក្នុងច្បាប់ ក្នុងការសំរេចលើកិច្ចការនិមួយៗ ពោលគឺត្រូវសំរេចអោយស្រប តាមច្បាប់តាមគោលការណ៍របស់រាជរដ្ឋាភិបាល និង ជៀសវាងមិនអោយជាន់ភារកិច្ចសិទ្ធិ អំណាចរបស់ក្រសួងស្ថាប័នដទៃឡើយ ។

២- ក្នុងករណីមានការសំរេច ដែលហួសពីក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងស្ថាប័នខ្លួន ប្រធានក្រសួងស្ថាប័ននោះ ត្រូវតែសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលជាមុន ជាអាទិ៍ដូចជាការចរចារ ឬចុះហត្ថលេខាលើអនុសញ្ញាកិច្ចព្រមព្រៀងពិធីសារ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្របច្ចេកទេសសន្តិសុខ និងការពារប្រទេស ជាមួយ បណ្តា ប្រទេសនានា ជាមួយអង្គការអន្តរជាតិអង្គការមិនមែនរដ្ឋាភិបាល ឬ ជាមួយក្រុមហ៊ុននានាត្រូវសុំការអនុញ្ញាត និងត្រូវមានការប្រគល់សិទ្ធិពី រាជរដ្ឋាភិបាលជាមុន ។ ការសំរេចក្នុងការតែងតាំងផ្លាស់ប្តូរ ឬបញ្ឈប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ ក្រសួងស្ថាប័នក៏ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមនិតិវិធី ដែលបានកំណត់ក្នុងច្បាប់ជាធរមាន ។ល ។

៣- រាល់លិខិតបទដ្ឋានរបស់ក្រសួងស្ថាប័នដែលមានលក្ខណៈផ្ទុយពី សេចក្តីណែនាំនេះ ត្រូវបាន ចាត់ទុកជានិរាករណ៍ ។

ក្រោយពេលទទួលបានសារាចរនេះ ប្រធានក្រសួងស្ថាប័នទាំងអស់ចំណុះរាជរដ្ឋាភិបាលត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤*

## ប្រកាសលេខ ១១ ៩១ ឧក ប្រក
## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល